

CHANGES PROGRAM | CAMBODIAN

# ការជ្រើសរើសគំរោងតម្លៃអគ្គិសនីមួយ

**ចំនួនអ្នកបង់សំរាប់អគ្គិសនី អាស្រ័យលើគំរោងតម្លៃ ដែលអ្នកជ្រើសរើស។**

**អ្នកអាចជ្រើសរើសគំរោងតម្លៃមួយ ចេញអគ្គិសនីរបស់អ្នក ដែលធ្វើការល្អបំផុត សំរាប់អ្នក និងគ្រួសាររបស់អ្នក។ គំរោងខ្លះគឺយោងលើ*ចំនួនប៉ុន្មាន* ដែលអ្នកប្រើអគ្គិសនី ហើយផ្សេងទៀត គឺយោងលើ*ពេលវេលា* ដែលអ្នកប្រើអគ្គិសនី។**

## តើការប្រើអគ្គិសនី ត្រូវបានវាស់ដូចម្ដេច?

ខ្នាតនៃរង្វាស់ដែលក្រុមហ៊ុនអគ្គិសនីរបស់អ្នកប្រើ ដើម្បីសំរេចចំនួនប៉ុន្មាន ដើម្បីចេញវិក្កយប័ត្រឲ្យអ្នកសំរាប់ចំនួនអគ្គិសនីដែលអ្នកប្រើ គឺហៅថា គីឡូវ៉ាត់ម៉ោង (kilowatt-hour, kWh)។

ឧទាហរណ៍ បើសិនអ្នកទិញសាំង អ្នកបង់សំរាប់ចំនួនសាំងដែលអ្នកទិញ; ឬបើសិនអ្នកទិញក្រណាត់ អ្នកអាចនឹងបង់ សំរាប់ចំនួនម៉ែត្រដែលអ្នកទិញ។ ជាមួយអគ្គិសនី អ្នកបង់សំរាប់ចំនួន គីឡូវ៉ាត់ម៉ោង នៃអគ្គិសនីដែលអ្នកប្រើ ក្នុងរយៈពេលជាក់លាក់។ ក្រុមហ៊ុនអគ្គិសនីរបស់អ្នក ប្រើរង្វាស់ដែលបានតទៅផ្ទះរបស់អ្នក ដើម្បីវាស់ការប្រើអគ្គិសនីរបស់អ្នក។ មួយ kWh គឺស្មើនឹងការប្រើ 1,000 វ៉ាត់ សំរាប់ 1 ម៉ោង។

## គំរោងតម្លៃ

ក្រុមហ៊ុនអគ្គិសនីនិមួយៗ មានគំរោងតម្លៃផ្សេងគ្នា។ អ្នកអាចជ្រើសរើសគំរោង ដែលសមរម្យល្អបំផុតសំរាប់កាលវិភាគ និងសេចក្ដីត្រូវការរបស់អ្នក។

### ថ្នាក់គំរោងតម្លៃ

គំរោងតម្លៃអគ្គិសនីរបស់អ្នក គឺត្រូវបានរៀបចំទៅជាថ្នាក់ៗ។ អ្នកចាប់ផ្ដើមនៅរយៈពេលវិក្កយប័ត្រនិមួយៗ នៅថ្នាក់ទាបបំផុត។ នេះគឺជាការបែងចែកថ្នាក់ទី 1 របស់អ្នក នៃគីឡូវ៉ាត់ម៉ោងដែលមានតម្លៃទាបបំផុតក្នុងមួយ kWh។ ខណៈណាអ្នកប្រើអគ្គិសនីច្រើន នោះអ្នកផ្លាស់ទៅថ្នាក់មួយទៀត ដែលតម្លៃក្នុងមួយ kWh កើនឡើង។ មធ្យោបាយល្អបំផុត ដើម្បីរក្សាតម្លៃថាមពលឲ្យទាប គឺដាក់កម្រិតការប្រើប្រាស់ថាមពលសរុបរបស់អ្នក ម្ល៉ោះហើយអ្នកបង់ថ្លៃវាតាមតម្លៃ (ឬថ្នាក់) ទាបបំផុត។

### គំរោងតាមវេលាប្រើ

តម្លៃមួយ kWh ក្នុងគំរោង តាមវេលាប្រើ (Time-Of-Use, TOU) អាស្រ័យលើវេលានៃថ្ងៃ និងថ្ងៃនៃអាទិត្យ ដែលអ្នកប្រើអគ្គិសនី។ បើសិនអ្នកបំរុងប្រើអគ្គិសនីរបស់អ្នក សំរាប់វេលានៅពេលតម្លៃទាបបំផុត និងសេចក្ដីត្រូវការលើខ្សែអគ្គិសនីគឺទាប អ្នកអាចនឹងសំចៃប្រាក់បាននៅក្នុងគំរោង TOU។ នៅក្នុងគំរោង TOU មានម៉ោងខ្លះត្រូវបានចាត់ទុកជា ម៉ោងប្រើខ្លាំង (នៅពេលអគ្គិសនីត្រូវបានប្រើច្រើនបំផុត)។ តម្លៃអគ្គិសនីដែលត្រូវបានប្រើច្រើន នៅអំឡុងម៉ោងប្រើខ្លាំង ក្នុងមួយ kWh។ ក្នុងករណីភាគច្រើន គំរោង TOU មានម៉ោងប្រើខ្លាំង ពីម៉ោង 4 ល្ងាច ដល់ 9 យប់។ មានតម្លៃខុសៗគ្នា នៅអំឡុងម៉ោងនៃចុងអាទិត្យខ្លះដែរ។

ក៏មានគំរោងតម្លៃខុសៗគ្នាដែរ សំរាប់អ្នកដែលមានភ្លើងសូឡា ឬអ្នកដែលបើករថយន្តអគ្គិសនី។

*បន្តនៅខាងខ្នង*

California Public Utilities Commission
505 Van Ness Ave.
San Francisco, CA 94102
415-703-2782
800-848-5580 (ឥតគិតថ្លៃ)
cpuc.ca.gov



## របៀបជ្រើសរើសគំរោងតម្លៃមួយ

ដើម្បីជ្រើសរើសគំរោងតម្លៃមួយ ជាបឋមគិតអំពីរបៀប និងពេលដែលអគ្គិសនីត្រូវបានប្រើ នៅក្នុងផ្ទះរបស់អ្នក។

- តើមានពេលវេលានៃថ្ងៃ នៅពេលសមាជិកគ្រួសាររបស់អ្នកទាំងអស់ នៅធ្វើការ និងនៅសាលា ឬទេ?
- តើពេលណាដែលកាលវិភាគរបស់អ្នក អនុញ្ញាតពេលវេលា សំរាប់ធ្វើកិច្ចការផ្ទះ?
- តើកាលវិភាគនៃគ្រួសាររបស់អ្នកបត់បែន ឬទេ? តើអ្នកអាចផ្លាស់ប្តូរថ្ងៃ ឬពេលវេលា ដែលអ្នកប្រើគ្រឿងអគ្គិសនីរបស់អ្នក ឬទេ?
- តើអ្នកជាមនុស្សឆាប់ក្រោក ឬតើអ្នកនៅយូរ នៅពេលយប់ឬទេ? តើកាលវិភាគនៃការងាររបស់អ្នកផ្លាស់ប្តូរញឹកញាប់ ឬវាគឺជាកាលវិភាគទៀតទាត់ ឬទេ?

សេចក្តីត្រូវការ និងកាលវិភាគ នៃមនុស្សក្នុងគ្រួសារម្នាក់ៗ គឺខុសៗគ្នា។ បើសិនអ្នកអាចផ្លាស់ប្តូរ ទៅពេលដែលអ្នកប្រើអគ្គិសនី ដូចជា ការផ្លាស់ប្តូរពេលវេលានៅពេលអ្នកធ្វើកិច្ចការផ្ទះ អ្នកអាចនឹងសំចៃប្រាក់បាន ជាមួយនឹងគំរោងតាមវេលាប្រើ។

គំរោង ឬក្រុមហ៊ុនអគ្គិសនីខ្លះ អនុញ្ញាតឲ្យអ្នកផ្លាស់ប្តូរគំរោងតម្លៃរបស់អ្នក មួយឆ្នាំម្តង។ ផ្សេងៗទៀតអាចនឹងតម្រូវឲ្យអ្នក ធ្វើការប្តេជ្ញាចិត្តចំនួន 12 ខែ ដើម្បីនៅក្នុងគំរោងតម្លៃដដែល មុននឹងអ្នកអាចដូរទៅគំរោងមួយទៀត។ ការផ្លាស់ប្តូរគំរោងតម្លៃរបស់អ្នក អាចនឹងប្រើពេលដល់ទៅការចេញវិក្កយប័ត្រពីរជុំ ដើម្បីមានប្រសិទ្ធិភាព។

ក្រុមហ៊ុនអគ្គិសនី មានប្រដាប់តាមអនទ្បាញ ដែលអាចណែនាំអ្នក ស្តីពីការជ្រើសរើសគំរោងមួយសំរាប់សេចក្តីត្រូវការរបស់អ្នក។

ផ្លាស់ប្តូរនូវការរៀបចំរបស់អ្នក អាចជួយអ្នកជាមួយការប្រើប្រដាប់ទាំងនោះ និងការជ្រើសរើសគំរោងតម្លៃ ដែលធ្វើការល្អបំផុត សំរាប់អ្នក និងគ្រួសាររបស់អ្នក។

### សំរាប់ព័ត៌មានថែមទៀត៖

ទស្សនា៖ www.cpuc.ca.gov/team-and-changes

អ៊ីមែល៖ cabteamandchanges@cpuc.ca.gov